# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :.១០៩...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់

********

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៩៥ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិកាជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- យោងស្មារតីអង្គប្រជុំរបស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ នាថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ២០០៧
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវផ្ទេរពីថវិការជាតិទៅគណនីមូលនិធិឃុំ សង្កាត់ សំរាប់រយៈពេលបីឆ្នាំ ដោយកំណត់ជាភាគរយនៃចំណូលចរន្តរបស់ថវិការដ្ឋដូចខាងក្រោម:

- ឆ្នាំថវិកា ២០០៨ : មិនត្រូវតិចជាង ២.៧០% នៃចំណូលចរន្តថវិការដ្ឋដែលបានអនុម័តឆ្នាំ២០០៧
- ឆ្នាំថវិកា ២០០៩ : មិនត្រូវតិចជាង ២.៧៥% នៃចំណូលចរន្តថវិការដ្ឋដែលបានអនុម័តឆ្នាំ២០០៨
- ឆ្នាំថវិកា ២០១០ : មិនត្រូវតិចជាង ២.៨០% នៃចំណូលចរន្តថវិការដ្ឋដែលបានអនុម័តឆ្នាំ២០០៩

**មាត្រា ២.-**

ការផ្ទេរថវិការដ្ឋប្រចាំឆ្នាំទៅក្នុងគណនីមូលនិធិឃុំ សង្កាត់ និងការផ្ទេរពីគណនីមូលនិធិឃុំ សង្កាត់សំរាប់ឃុំ សង្កាត់នីមួយៗត្រូវអនុវត្តបណ្តើរតាមការកំណត់ដូចខាងក្រោម:

- យ៉ាងតិច ៥០ភាគរយ នៃចំនួនផ្ទេរសរុប អោយបានមុនថ្ងៃទី ៣១ ខែ ឧសភា
- យ៉ាងតិច ៨០ភាគរយ នៃចំនួនផ្ទេរសរុប អោយបានមុនថ្ងៃទី ៣១ ខែ សីហា
- និង ១០០ ភាគរយ នៃចំនួនផ្ទេរសរុប អោយបានមុនថ្ងៃទី ៣១ ខែ តុលា

**មាត្រា ៣.-**

ធនធានមូលនិធិសរុប ដែលបានមកពីការចូលរួមរបស់ថវិការដ្ឋដូចដែលមានកំនត់ក្នុងមាត្រា២ នៃអនុក្រឹត្យនេះ ការចូលរួមពីជំនួយឥតសំណង និងការខ្ចីដែលបានមកពីដៃគូអភិវឌ្ឍន៍នានា ត្រូវបែងចែកជាពីរសមាសភាគ ហើយត្រូវបានកំណត់សមាមាត្រសំរាប់រយៈពេលពីឆ្នាំ២០០៨ ដល់ ២០១០ សំរាប់សមាសភាគនីមួយៗដូចខាងក្រោម:

| ឆ្នាំថវិកា | សមាសភាគរដ្ឋបាលទូទៅ | សមាសភាគអភិវឌ្ឍន៍មូលដ្ឋាន |
|---|---|---|
| ឆ្នាំថវិកា ២០០៨ | ៣៣% | ៦៧% |
| ឆ្នាំថវិកា ២០០៩ | ២៩% | ៧១% |
| ឆ្នាំថវិកា ២០១០ | ២៦% | ៧៤% |

**មាត្រា ៤.-**

ធនធាននៃសមាសភាគរដ្ឋបាលទូទៅ ត្រូវបានប្រើប្រាស់សំរាប់ចំណាយទាំងឡាយ ដូចបានចែងក្នុងកថាខ័ណ្ឌទី២ មាត្រា១៥ នៃអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់ និងសំរាប់ចំណាយឧបត្ថម្ភដល់មន្ត្រីភូមិតាមរបបកំណត់ជាធរមាន។

ធនធាននៃសមាសភាគរដ្ឋបាលទូទៅរួមមាន ចំណាយសំរាប់ប្រតិបត្តិការរដ្ឋបាល ចំណាយសំរាប់ប្រាក់បំណាច់ក្រុមប្រឹក្សាឃុំ សង្កាត់ និងចំណាយសំរាប់ឧបត្ថម្ភមន្ត្រីភូមិ។

ចំណាយសំរាប់ប្រតិបត្តិការរដ្ឋបាល ត្រូវបានគណនាដោយយកធនធាននៃសមាសភាគរដ្ឋបាលទូទៅដកចេញនូវចំណាយសំរាប់ប្រាក់បំណាច់ក្រុមប្រឹក្សាឃុំ សង្កាត់ និងចំណាយសំរាប់ឧបត្ថម្ភមន្ត្រីភូមិ រួចទើបធ្វើការបែងចែកទៅតាមសមាមាត្រនៃចំនួនក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ។

**មាត្រា ៥.-**

ធនធាននៃសមាសភាគអភិវឌ្ឍន៏មូលដ្ឋានត្រូវបានប្រើប្រាស់សំរាប់ចំណាយទាំងឡាយ ដូចដែលមានចែងក្នុងកថាខ័ណ្ឌ ទី៣ នៃមាត្រា ១៥ នៃអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់ និងត្រូវបានវិភាជន៏ទៅអោយឃុំ សង្កាត់នីមួយៗ តាមការគណនាដោយផ្អែកលើសន្ទស្សន៏ដូចខាងក្រោមៈ

- ចំណែកស្មើគ្នាជាមូលដ្ឋាន
- ចំនួនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់នីមួយៗ (ដោយផ្អែកតាមឯកសាររបស់ក្រសួងផែនការ)
- សន្ទស្សន៏ភាពក្រីក្រនៃឃុំ សង្កាត់នីមួយៗ (ដោយផ្អែកតាមឯកសាររបស់ក្រសួងផែនការ)

សមាមាត្រនៃមូលនិធិអភិវឌ្ឍន៏មូលដ្ឋាន សំរាប់សន្ទស្សន៏នីមួយៗខាងលើ ត្រូវកំណត់ដូចខាងក្រោមៈ

| ឆ្នាំថវិកា | ចំណែកស្មើគ្នាជាមូលដ្ឋាន | ចំនួនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់នីមួយៗ | សន្ទស្សន៏ភាពក្រីក្រក្នុងឃុំ សង្កាត់នីមួយៗ |
|---|---|---|---|
| ឆ្នាំថវិកា ២០០៨ | ៣៥% | ៣៥% | ៣០% |
| ឆ្នាំថវិកា ២០០៩ | ៣៥% | ៣៥% | ៣០% |
| ឆ្នាំថវិកា ២០១០ | ៣៥%. | ៣៥% | ៣០% |

**មាត្រា ៦.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវគណនា និងជូនដំណឹងជាផ្លូវការអំពីចំនួនធនធានវិភាជន៏ ដែលឃុំ សង្កាត់នីមួយៗត្រូវទទួលបានសំរាប់ឆ្នាំបន្ទាប់យ៉ាងយូរបំផុតត្រឹមថ្ងៃទី ០១ ខែ តុលា នៃឆ្នាំថវិកាកំពុងអនុវត្ត។ គំរោងថវិកាត្រូវរៀបចំឡើងក្រោមការទទួលខុសត្រូវរបស់មេឃុំ ចៅសង្កាត់ ហើយត្រូវដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីពិនិត្យ និងអនុម័ត។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុម័តគំរោងថវិកានាកិច្ចប្រជុំជាសាធារណៈ អោយបានមុនថ្ងៃទី ៣១ ខែ

តុលា បន្ទាប់មកមេឃុំ ចៅសង្កាត់ ត្រូវបញ្ជូនគំរោងថវិកា ដែលបានអនុម័តរួចទៅអភិបាលខេត្ត-ក្រុង អោយបានមុនថ្ងៃទី ៥ ខែ វិច្ឆិកា ដើម្បីសុំការបញ្ជាក់ទទួលស្គាល់ ពីអភិបាលខេត្ត-ក្រុង ដោយមិនអោយហួសថ្ងៃទី ៣១ ខែ ធ្នូ នៃឆ្នាំជាក់ហិត។

**មាត្រា ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលគ្រប់ខេត្ត-ក្រុង ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់ទាំងអស់ត្រូវអនុវត្តតាមអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ៨ ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីដើម្បីចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចចែងក្នុងមាត្រា ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ